គម្រោងស្ពានខ្ពស់នៅភាគខាងលិចទីក្រុងសៀអាថុល

WEST SEATTLE HIGH-RISE BRIDGE PROJECT

ខែមេសាឆ្នាំ ២០២១

# ពង្រីកការបើកបរចូលទៅកាន់ស្ពាន SPOKANE ST SWING BRIDGE ( ស្ពានទាប )

មើលថាតើអ្នកមានលក្ខណៈអាចបើកបរចូលទៅបានទេ!

## របៀបដាក់ពាក្យសុំ

សូមដាក់ពាក្យសុំបើកបរចូលទៅកាន់ស្ពានទាបតាមនេះ www.seattle.gov/transportation/lowbridge ឬដោយប្រើលេខកូដ QR នៅលើទំព័រនេះ។ ពាក្យសុំមានជាភាសាដូចខាងក្រោម៖ អង់គ្លេស, អេស្ប៉ាញ៉ុល, កូរ៉េ, សូម៉ាលី, ចិន (ប្រពៃណី), វៀតណាម, អូរ៉ូមូ និង ខ្មែរ។ ដើម្បីស្នើសុំពាក្យសុំជាភាសាផ្សេងទៀតឬជាទម្រង់ក្រដាសសូមទាក់ទងមកយើងខ្ញុំតាម WestSeattleBridge@seattle.gov ឬ ២០៦-៤០០-៧៥១១ ។



## ក្រុមអ្នកប្រើប្រាស់ដែលអាចសុំបើកបរចូលប្រើបាន

ការបើកបរចូលទៅកាន់ស្ពានទាបនៅពេលថ្ងៃត្រូវបានរឹតត្បិតដើម្បីធានាថារថយន្តធំដឹកអ្នកដំណើរ ដឹកជញ្ជូនទំនិញ និងរថយន្តសង្គ្រោះបន្ទាន់អាចធ្វើដំណើរទៅមកពីខាងលិចក្រុងសៀអាថុលបានប្រកបដោយប្រសិទ្ធិភាព។ ក្រុមខាងក្រោមអាចដាក់ពាក្យសុំប្រើប្រាស់ស្ពានទាបបានដោយមានកំរិត។

- មនុស្សដែលធ្វើដំណើរទៅនិងមកពីការព្យាបាលសង្គ្រោះជីវិតចាំបាច់ ( តំរូវមានលិខិតអនុញ្ញាតចេញពីអ្នកផ្តល់សេវាព្យាបាលរបស់អ្នក ) តាមរយៈភាគខាងលិចទីក្រុងសៀអាថុល; រួមបញ្ចូលទាំងការបើកបរទៅរកការព្យាបាលតាមរយៈសាឡាង Fauntleroy Ferry
- បុគ្គលិកពេទ្យដែលធ្វើការតាមការហៅ ( សម្រាប់តែការធ្វើដំណើរទៅនិងមកពីវេនធ្វើការងារតែប៉ុណ្ណោះ តំរូវអោយមានការបញ្ជាក់ពីនិយោជិក( កន្លែងធ្វើការ ) ផងដែរ
- ភោជនីយដ្ឋាននិងអាជីវកម្មលក់របស់របរដែលមានមូលដ្ឋាននៅតំបន់ខាងលិចក្រុងសៀអាថុល West Seattle ( កំរិតចំពោះតែការធ្វើដំណើរបន្ទាន់ដើម្បីទៅយកឧបករណ៍ឬការផ្គត់ផ្គង់តែប៉ុណ្ណោះ )
- រថយន្តជិះជាក្រុមរួមគ្នា ( ឡានវ៉ែនជិះរួម ឡានធំឬឡានរដ្ឋាការជិះរួមគ្នាដែលមានលេខផ្លាកឡានជិះរួមគ្នាចេញដោយរដ្ឋ មិនរាប់បញ្ចូលឡានដឹកភ្ញៀវ Uber/Lyft ឡានតាក់ស៊ីទេ )
- អាជីវកម្មតាមសមុទ្រនិងឧស្សាហកម្មស្ថិតនៅជិតស្ពានទាប ( កំរិតត្រឹមតែការធ្វើដំណើរបន្ទាន់ដើម្បីទៅយកឧបករណ៍ឬដឹកជញ្ជូនបុគ្គលិកសំខាន់ៗ ) ។
- រថយន្តរបស់រដ្ឋាភិបាល ( កំណត់ចំពោះការធ្វើដំណើរបន្ទាន់/មិនបានគ្រោងទុក )

### សេវាកម្មភាសា

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបំពេញពាក្យសុំ ឬមានសំណួរអ្វី អ្នកអាចទូរស័ព្ទមក (២០៦) ៤០០-៧៥១១ ហើយទុកសារជាសំឡេងឬផ្ញើសារអ៊ីមែលមក WestSeattleBridge@seattle.gov ។ សូមទុកឈ្មោះរបស់អ្នក ព័ត៌មានទំនាក់ទំនងនិងតម្រូវការភាសាអ្វី ភ្នាក់ងារម្នាក់នឹងទូរស័ព្ទមកអ្នកវិញ។

**!** អ្នកត្រូវដាក់ពាក្យសុំ, ផ្តល់ផ្លាកលេខឡានរបស់អ្នក, មានលក្ខណៈស្របតាមគោលការណ៍, និងទទួលបានការយល់ព្រមពីយានយកដ្ឋានដឹកជញ្ជូនក្រុងសៀអាថុល SDOT មុនពេលអ្នកអាចប្រើស្ពានទាប ការបើកបរចេញចូលស្ពានទាបបណ្តោះអាសន្នគឺអនុញ្ញាតរហូតដល់ចុងឆ្នាំ ២០២១។ តែប្រសិនប

### ព័ត៌មានគម្រោងនិងទំនាក់ទំនង

គេហទំព័រ៖ www.seattle.gov/transportation/lowbridge
អសយដ្ឋានសារអ៊ីមែល៖ WestSeattleBridge@seattle.gov
លេខទូរស័ព្ទ៖ (២០៦) ៤០០-៧៥១១

Seattle Department of Transportation

មានចរាចរណ៍ច្រើនពេកនៅលើស្ពានទាប យើងអាចកាត់បន្ថយការអនុញ្ញាតិចរាចរណ៍ឆ្លងកាត់ជាងនេះ ដើម្បីរក្សានិងអាចទុកចិត្តបានសម្រាប់ការធ្វើដំណើររបស់រថយន្តសង្គ្រោះបន្ទាន់។

ស្ពានអាកាសត្រូវបានគេរំពឹងថានឹងបើកដំណើរការឡើងវិញនៅពាក់កណ្តាលឆ្នាំ ២០២២

## លនយោបាយដើម្បីជិះចូលស្ពានទាប

ស្ពានទាបត្រូវបានបិទចំពោះយានយន្តដែលមិនមានការអនុញ្ញាត (មិនមានយានយន្តផ្ទាល់ខ្លួន, ម៉ូតូឬវេស្ពា, ឡានតាក់ស៊ី, យានយន្តហៅជិះដោយខ្សែរប្រព័ន្ធដូចជា Uber និង Lyft ជាដើមឡើយ)

- ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ៖ ចាប់ពីម៉ោង ៥ ព្រឹក ដល់ ៩ យប់
- ថ្ងៃសៅរ៍និងថ្ងៃអាទិត្យ៖ ចាប់ពីម៉ោង ៨ ព្រឹក ដល់ ៩ យប់





យានយន្តដែលគ្មានការអនុញ្ញាតនឹងទទួលបាននូវការផាកពិន័យ ៧៥ ដុល្លារ រៀងរាល់ការធ្វើដំណើរឆ្លងកាត់ស្ពានទាបម្តងក្នុងអំឡុងពេលម៉ោងដែលបានកំរិតបន្តឹងនេះ។

ចំពោះអ្នកបើកបររថយន្តសង្គ្រោះបន្ទាន់ ឡានក្រុងដឹកអ្នកដំណើរ ឡានធំដឹកទំនិញ អាចប្រើប្រាស់ស្ពានទាបនេះបានគ្រប់ពេលវេលា មិនចាំបាច់ដាក់ពាក្យសុំបើកបរចូលឬផ្តល់លេខស្លាករថយន្តមកនាយកដ្ឋានដឹកជញ្ជូនក្រុងសៀអាថុល SDOT ឡើយ។



ផ្លូវសម្រាប់អ្នកថ្មើរជើងនៅស្ពានទាបបើកពេញមួយថ្ងៃនិងគ្រប់ម៉ោងសម្រាប់អ្នកដើរ រុកិល ជិះរទេះកង់ប្រើអគ្គិសនីឬកង់។

## តើមានអ្វីកើតឡើងប្រសិនបើមានអាសន្ន ហើយខ្ញុំត្រូវការបើកឆ្លងកាត់ស្ពានទាប?

យើងដឹងហើយថាភាពអាសន្នអាចកើតឡើង ហើយអ្នកប្រហែលជាត្រូវបើកឡានទៅមន្ទីរពេទ្យជំនួសការហៅរថយន្តសង្គ្រោះបន្ទាន់ ឬធ្វើដំណើរឆ្លងកាត់ស្ពានសម្រាប់ភាពអាសន្នផ្សេងៗទៀត។ លើសំបុត្រផាកពិន័យ ៧៥ ដុល្លារនោះ នឹងមានការណែនាំអំពីវិធីតវ៉ាការផាកពិន័យនេះ។ យើងមិនអាចធានាថាអ្នកនឹងមិនបង់ប្រាក់ពិន័យខុសនេះទេ ព្រោះការសំរេចនេះគឺជាសិទ្ធរបស់តុលាការក្រុងសៀអាថុល។